**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :..............០០៣/១៧............ក.ប/ស.ណ.ន.ក.ក.ស

# សេចក្តីណែនាំ

# ស្តីពី

# ការកំណត់ទំហំ និងគំរូសញ្ញាបត្របច្ចេកទេស ឬឯកទេស

ដើម្បីឲ្យមានការឯកភាពគ្នាក្នុងការចេញសញ្ញាបត្របច្ចេកទេស ឬឯកទេស ដែលស្ថិតនៅក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមធ្វើការណែនាំដូចតទៅ៖

**១-ទំហំ និងខ្នាត**

គ្រប់កម្រិតសញ្ញាបត្រទាំងអស់ត្រូវប្រើទំហំ និងខ្នាត បណ្តោយ ៣០ស.ម គុណទទឹង ២០ស.ម។

**២- ប្រភេទ និងពណ៌ក្រដាស**

គ្រប់កម្រិតសញ្ញាបត្រទាំងអស់ត្រូវប្រើប្រភេទក្រដាសដែលមានទំងន់ធ្ងន់ជាង ១០០ក្រាម និងពណ៌សពងមាន់។

**៣-ពណ៌ស៊ុម**

- វិញ្ញាបនបត្រវិជ្ជាជីវៈ ត្រូវប្រើស៊ុមពណ៌ខៀវ
- សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ ឬ ២ ឬ ៣ ត្រូវប្រើស៊ុមពណ៌ក្រហមឈាមជ្រូក
- សញ្ញាបត្រជាន់ខ្ពស់ ឬបរិញ្ញាបត្ររង បច្ចេកទេស ឬឯកទេស ត្រូវប្រើស៊ុមពណ៌បៃតង
- បរិញ្ញាបត្របច្ចេកវិទ្យា ឬឯកទេស សញ្ញាបត្រវិស្វករ ត្រូវប្រើស៊ុមពណ៌ទឹកមាស
- បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា ឬឯកទេស ត្រូវប្រើស៊ុមពណ៌ស្វាយ
- បណ្ឌិតបច្ចេកវិទ្យា ឬឯកទេស ត្រូវប្រើស៊ុមពណ៌ទឹកក្រូច

ទទួលបានសេចក្តីណែនាំនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី នាយក នាយិកា គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រោមឱវាទក្រសួងទាំងអស់ ត្រូវអនុវត្តនូវខ្លឹមសារនៃសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាព។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន៖**

- អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- គ្រប់ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្ត

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ :(០២៣)៨៨២៧៦៩*